## ៣. ការរៀបចំកម្មវិធីសិក្សា

៣.១ ក្រសួងអប់រំ យុវជន និង កីឡា (អ.យ.ក ) មានភារៈផ្តល់មូលនិធិ ផ្តល់គ្រូបង្រៀន ផ្តល់មធ្យោបាយរូបវ័ន្ត និង ប្រភពធនធានផ្សេងៗទៀត ដល់អ្វីដែលមានចែងក្នុង **កម្មវិធីសិក្សាជាតិ** ។

៣.២ **កម្មវិធីសិក្សាជាតិ** ត្រូវកំនត់អោយបង្រៀន ៣៨ សប្តាហ៍ ក្នុងមួយឆ្នាំសិក្សា។

៣.៣ សាលារៀន សហគមន៍មូលដ្ឋាន អង្គការសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និង អ្នកផ្តល់សេវាកម្មអប់រំឯកជន ត្រូវអភិវឌ្ឍកម្មវិធីសិក្សាដើម្បីជួយបង្កើនគុណភាព និង ជួយពង្រីក **កម្មវិធីសិក្សាជាតិ** អោយកាន់តែមានលក្ខណៈល្អប្រសើរ។

៣.៤ សាលារៀនត្រូវបង្កើនភាពជាដៃគូជាមួយមាតាបិតាសិស្ស សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល ហើយត្រូវអភិវឌ្ឍ **កម្មវិធីបំនិនជីវិតតាមមូលដ្ឋាន** (**ក.ប.ជ.ម.**) ដែលមានពី ២ ទៅ ៥ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ (មួយម៉ោងសិក្សាមានរយៈពេល ៤០ នាទី សំរាប់បឋមសិក្សា និង ៥០ នាទី សំរាប់ មធ្យមសិក្សា ) ដើម្បី ជួយបំពេញ **កម្មវិធីសិក្សាជាតិ**។

៣.៥ បំនែងចែកម៉ោងសិក្សាសំរាប់ **កម្មវិធីសិក្សាជាតិ** និង សំរាប់ **ក.ប.ជ.ម.** មានដូចខាងក្រោម :

| **បឋមសិក្សា** | | |
|---|---|---|
| **កម្មវិធីសិក្សាជាតិ** | **កម្មវិធីបំនិនជីវិតតាមមូលដ្ឋាន** | **សរុប** |
| ៥ម៉ោងសិក្សាក្នុង១ថ្ងៃដែល ១ម៉ោងសិក្សាមាន ៤០ នាទី (២៥×៤០នាទីក្នុងមួយសប្តាហ៍) | ២ -៥ម៉ោងសិក្សាក្នុង ១ សប្តាហ៍ ១ម៉ោងសិក្សាមាន ៤០ នាទី | ២៧-៣០ម៉ោងសិក្សាក្នុង១សប្តាហ៍ |
| **មធ្យមសិក្សា (ថ្នាក់ទី ៧ ~ ១០ )** | | |
| ៣០ម៉ោងសិក្សាក្នុង១សប្តាហ៍ ១ម៉ោងសិក្សាមាន ៥០ នាទី (៣០×៥០នាទីក្នុងមួយសប្តាហ៍) | ២ -៥ម៉ោងសិក្សាក្នុង ១ សប្តាហ៍ ១ម៉ោងសិក្សាមាន ៥០ នាទី | ៣២-៣៥ម៉ោងសិក្សាក្នុង១សប្តាហ៍ |
| **មធ្យមសិក្សា (ថ្នាក់ទី ១១ ~ ១២ )** | | |
| ៣២ម៉ោងសិក្សាក្នុង១សប្តាហ៍ ១ម៉ោងសិក្សាមាន ៥០ នាទី (៣២×៥០នាទីក្នុងមួយសប្តាហ៍) | | ៣២ម៉ោងសិក្សាក្នុង១សប្តាហ៍ ១ម៉ោងសិក្សាមាន ៥០ នាទី |

៣.៦ គោលបំនងនៃ **ក.ប.ជ.ម.** គឺ

3.6.1 ផ្តល់ឱកាសអោយសាលារៀនសហការជាមួយ មាតាបិតាសិស្ស សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល ក្នុងការរៀបចំខ្លឹមសារកម្មវិធីសិក្សាមូលដ្ឋានមួយ ដែលពាក់ព័ន្ធទៅនឹងតំរូវការជាក់លាក់របស់សិស្សតាមមូលដ្ឋានរបស់ពួកគេ។

3.6.2 ផ្តល់ឱកាសអោយសាលារៀនប្រើពេលវេលាក្នុងកម្មវិធីសិក្សាសំរាប់ធ្វើសកម្មភាពបន្ថែមដូចជាសេវាកម្ម សង្គម ឬ សកម្មភាពចលនាយុវជន ដែលអាចជួយអោយសិស្សមានទំលាប់ទទួលខុសត្រូវ និង មាន

ទំនុកចិត្តថែមទៀតលើខ្លួនគេ។ទំលាប់ទាំងនេះត្រូវបណ្តុះអោយបានរឹងមាំនៅកំរិតបឋមសិក្សាដោយប្រើ ពេលវេលាដែល មានក្នុង **គ.ប.ជ.ម.** ។

៣.៧ សាលារៀនមានភារៈទទួលខុសត្រូវក្នុងការរៀបចំរកមូលនិធិ រកបុគ្គលិក ព្រមទាំងបំពាក់សំភាររូបវ័ន្ត និង បរិក្ខារ សំរាប់ **គ.ប.ជ.ម.** ដោយសហការជាដៃគូជាមួយមាតាបិតាសិស្ស សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល។

៣.៨ នៅថ្នាក់ទី១១ និង ១២ នៃមធ្យមសិក្សាទុតិយភូមិ កម្មវិធីសិក្សាត្រូវបានផ្តល់តាមរយៈមុខវិជ្ជា **កម្មវិធីសិក្សាជាតិ** និង **កម្មវិធីអប់រំវិជ្ជាជីវៈជំរើស**។ ចំនែកនៅថ្នាក់ទី១០មាន **កម្មវិធីសិក្សាជាតិ** និង **កម្មវិធីបំនិនជីវិតតាម មូលដ្ឋាន**។

៣.៩ គោលបំនងនៃ **កម្មវិធីអប់រំវិជ្ជាជីវៈជំរើស** គឺផ្តល់ឳកាសអោយសិស្សចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្តល់ដោយមូលដ្ឋាន។

៣.១០ មុខវិជ្ជាក្នុង **កម្មវិធីអប់រំវិជ្ជាជីវៈជំរើស** ត្រូវផ្តល់ដោយក្រសួង អ.យ.ក និង/ឬ ផ្នែកសេវាកម្មអប់រំឯកជន ក្នុង លក្ខណៈភាពជាដៃគូ ដែលទទួលស្គាល់និងអនុញ្ញាត (ចុះបញ្ជី)ដោយក្រសួង អ.យ.ក។ សិស្សដែលសិក្សាក្នុង **កម្មវិធីអប់រំវិជ្ជាជីវៈជំរើស** នឹងទទួលការផ្គត់ផ្គង់មូលនិធិដោយ ក្រសួង អ.យ.ក ដៃគូសហការ ឬ បង់ថ្លៃ។

៣.១១ កម្មវិធីសិក្សាសំរាប់មុខវិជ្ជាក្នុង **កម្មវិធីអប់រំវិជ្ជាជីវៈជំរើស** ត្រូវទទួលការយល់ព្រមពីក្រសួង អ.យ.ក ហើយ វង្វាយតំលៃមុខវិជ្ជាទាំងនេះក៏ត្រូវទទួលការណែនាំពីក្រសួង អ.យ.ក ដែរ។

៣.១២ កម្មវិធីបង្រៀនសំរាប់ **កម្មវិធីសិក្សាជាតិ** ក្នុងសាលារៀននីមួយៗ ត្រូវតែ :

- ជាការបង្រៀនតាមរចនាសម្ព័ន្ធ មានលំដាប់លំដោយតាមប្រព័ន្ធត្រឹមត្រូវ និង ជាគោលវិធីសិស្សមជ្ឈមណ្ឌល
- មានសកម្មភាពក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន
- អោយសិស្សរៀនទាំងទ្រឹស្តី ទាំងអនុវត្តន៍
- ផ្តល់ឳកាសសំរាប់ការលើកទឹកចិត្ត និង ការអភិវឌ្ឍភាពច្នៃប្រឌិត និង ប្រឌិតញាណរបស់សិស្ស។

3.13 ភាសាបរទេសពីរ គឺភាសាអង់គ្លេសនិងបារាំង ត្រូវផ្តល់ជាផ្នែកមួយនៃ កម្មវិធីសិក្សាជាតិ សំរាប់សិស្សគ្រប់គ្នាពី ថ្នាក់ទី ៥ ដល់ទី ១២ ។ សិស្សម្នាក់ៗអាចជ្រើសរើសភាសាបរទេសតែមួយគត់ (បារាំង ឬ អង់គ្លេស ) ដើម្បី សិក្សា។ ក្នុងដំនាក់កាលទី១(២០០៥-២០០៩) នៅបឋមសិក្សា ថ្នាក់ទី៥ និង ទី៦ ភាសាបរទេសត្រូវបង្រៀនដល់ សិស្សតាមលទ្ធភាពសាលារៀន។ ក្រសួងអ.យ.ក. នឹងជំរុញ សាលារៀនអោយបង្រៀនភាសាបរទេសដោយប្រើ ធនធានឧបត្ថម្ភពី ខាងក្រៅ និងប្រើម៉ោងក្នុងកម្មវិធីបំនិនជីវិតតាមមូលដ្ឋាន។

៣។១៤ សាលារៀនត្រូវតែផ្តល់ឳកាសស្មើគ្នា រវាងសិស្សប្រុស និង សិស្សស្រី ក្នុងការទទួលគ្រប់សមាសភាគអប់រំដែល មានក្នុងកម្មវិធីសិក្សា ។ សាលារៀនគួរតែខំប្រឹងប្រែងជាពិសេសក្នុងការជួយសំរួលអោយសិស្សស្រីបានចូលរួម គ្រប់ទិដ្ឋភាពនៃកម្មវិធីសិក្សា។

៣.១៥ សាលារៀននីមួយៗគួរផ្តល់ឳកាសសំរាប់ជំរុញសិស្សពូកែ។ ការងារទាំងនេះអាចធ្វើបាន ដោយអោយសិស្សពូកែ និង សិស្សដែលមានកោសល្យបង្កើនសមត្ថភាពពួកគេ តាមរយៈការសិក្សាធម្មតានៅក្នុងថ្នាក់ តាមកម្មវិធីសិក្សាដែល មានស្រាប់ និង តាមរយៈការផ្តល់កម្មវិធីពិសេសៗ ដោយប្រើម៉ោងសិក្សា ដែលបានកំនត់នៅក្នុង **គ.ប.ជ.ម.**។

៣.១៦ សាលារៀនត្រូវជួយជ្រោមជ្រែងសិស្សដែលមានការលំបាកក្នុងការសិក្សា តាមរយៈជំនួយរបស់គ្រូក្នុងម៉ោងសិក្សា និងតាមរយៈកម្មវិធីពិសេសដែលបានកំនត់ក្នុង **គ.ប.ជ.ម.**។

៣.១៧ សាលារៀននីមួយៗត្រូវព្យាយាមផ្តល់សិទ្ធិទទួលការអប់រំក្នុងកម្មវិធីសិក្សា ដល់សិស្សពិការ។

៣.១៨ ចំពោះកម្មវិធីវង្វាយតំលៃ សាលារៀននីមួយៗគួរតែផ្តល់ការបញ្ជាក់យ៉ាងច្បាស់លាស់ដល់សិស្ស និងមាតាបិតាសិស្ស អំពីកំរិតលទ្ធផលដែលសិស្សទទួលបាន ធៀបទៅនឹងកំរិតស្តង់ដាដែលរំពឹងទុកក្នុងកម្មវិធីសិក្សាថ្មី និង ធៀបទៅនឹងស្តង់ដានៃការសិក្សាសំរាប់សិស្សថ្នាក់ទី ៣ ទី៦ ទី៩ និងទី១២ (ស្របតាមគោលនយោបាយចែងក្នុង **ការអប់រំសំរាប់ទាំងអស់គ្នា** ទំព័រ៦០ )។ វង្វាយតំលៃនេះគួរតែបង្ហាញដល់សិស្សនូវពត៌មានច្បាស់លាស់អំពីចំនុចខ្លាំង ចំនុចខ្សោយ និងជំហានដែលពួកគេត្រូវអនុវត្ត ដើម្បីបង្កើនលទ្ធផលសិក្សារបស់ពួកគេ។ សាលារៀនត្រូវរាយការណ៍ជូនមាតាបិតាសិស្សពីការចូលរួមរបស់សិស្ស ពីសមិទ្ធិរបស់សិស្សលើគ្រប់សមាសភាគនៃកម្មវិធីសិក្សាដែលមានក្នុងសាលារៀន។

៣.១៩ ភាសាខ្មែរជាភាសាយានក្នុងការបង្រៀន។ សៀវភៅសិក្សាត្រូវបោះពុម្ពជាភាសាខ្មែរ លើកលែងតែសៀវភៅមុខវិជ្ជាភាសាបរទេស។ នៅសាលារៀនណាដែលមានសិស្សភាគច្រើននិយាយភាសាជនជាតិភាគតិច គ្រូអាចប្រើភាសាជនជាតិខ្លះៗបានក្នុងការបង្រៀន ហើយគ្រូបង្រៀនគួរតែបកប្រែវាក្យស័ព្ទគន្លឹះសំខាន់ៗដែលមានក្នុងសៀវភៅសិក្សាពីភាសាខ្មែរទៅភាសាជនជាតិទាំងនោះ ដើម្បីជាមធ្យោបាយជួយសិស្សក្នុងការសិក្សា។

៣.២០ ខ្លឹមសារកម្មវិធីសិក្សា លទ្ធផលចំនេះដឹង លទ្ធផលបំនិនរំពឹងទុក ព្រមទាំងស្តង់ដាដែលទាក់ទងទៅនឹងស្តង់ដានៃកម្មវិធីសិក្សាជាតិ នឹងមានចែងក្នុងឯកសារថ្មី **កម្មវិធីសិក្សាជាតិ**។

៣.២១ ក្រសួង អ.យ.ក មានភារកិច្ចអភិវឌ្ឍកម្មវិធីសិក្សា និង ស្តង់ដាមុខវិជ្ជានីមួយៗដែលមានក្នុង **កម្មវិធីសិក្សាជាតិ** និងមានសមត្ថកិច្ចពិនិត្យ និងអនុញ្ញាតអោយបោះពុម្ពផ្សាយឬផលិតរាល់សៀវភៅសិក្សាគោល សៀវភៅអំនានបន្ថែម សំភារឧបទេស ដែលបំរើអោយការបង្រៀន និង រៀននៅក្នុងសាលារៀន។

៣.២២ ក្នុងគោលបំនងសំរួលការរៀបចំកម្មវិធីសិក្សាសំរាប់អនុវត្តនិងអភិវឌ្ឍស្តង់ដា **កម្មវិធីសិក្សាជាតិ** សំរាប់**ការអប់រំ មូលដ្ឋាន** ត្រូវបែងចែកជា ៣ ដំនាក់ ដូចតទៅ :

- បឋមសិក្សា ថ្នាក់ទី ១-៣
- បឋមសិក្សា ថ្នាក់ទី ៤-៦
- មធ្យមសិក្សាបឋមភូមិ ថ្នាក់ទី ៧ -៩

**កម្មវិធីសិក្សាជាតិ** សំរាប់ **ការអប់រំនៅមធ្យមសិក្សាទុតិយភូមិ** ត្រូវបែងចែកជា ២ ដំនាក់ ដូចតទៅ :

- ថ្នាក់ទី ១០

ថ្នាក់ទី១១ - ១២ ។